# ភ្នំនាងកង្រី



## ក. សិក្សាពាក្យគន្លឹះ

- ពុត (ន) : ដំណើរបាំងទោសខ្លួន ដំណើរបិញរបុញ កិច្ចកលមាយា ការក្លែងបង្វែងដំណើរ ឱ្យឃ្លាតចាកសេចក្ដីពិត ។
- ញុះញង់ (កិ) : ញុះញយៗ គឺនិយាយចាក់រុកនាំអុជអាលឱ្យអ្នកដទៃ ធ្វើកិច្ចការអ្វីៗដែលមិនគប្បីឱ្យឈ្លោះទាស់ទែងគ្នា ។
- គភ៌ (ន) : ផ្ទៃពោះ (មានផ្ទៃពោះ) ។
- ក្សេមក្សាន្ត (គុ) : ដែលមានសេចក្ដីសុខសាន្ត ។
- ព្រះទិវង្គត (កិ. ឬ គុ) : ស្លាប់ ។

## ខ. អភិវឌ្ឍន៍បំណិន

ដើម្បីទទួលលទ្ធផលល្អក្នុងការអាន អ្នកគប្បីយកចិត្តទុកដាក់ត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងប្រភេទអក្សរសិល្ប៍ លក្ខណតថៈរបស់រឿង គំនិតសំខាន់បង្កប់ និងកាលអាកាស ។



## គ. អត្ថបទ

កាលពីព្រេងនាយ មានសេដ្ឋីនៅនគរមួយជាមនុស្សឥតកូន បាននាំប្រពន្ធទៅបន់ស្រន់សុំកូននៅដើមជ្រៃមួយ ។ ក្រោយពីបន់ស្រន់រួចប្រពន្ធមានកូនរហូតដល់១២នាក់សុទ្ធតែស្រី ។ លុះបានកូនហើយសេដ្ឋីធ្លាក់ខ្លួនជាអ្នកទ័លក្រ រកអាហារចិញ្ចឹមកូនគ្មានក៏បរវទេះដឹកកូនទាំង១២នាក់ទៅប្រោសចោលក្នុងព្រៃជ្រៅមួយ ។

ក្រោយពីឪពុកប្រោសចោល កូនទាំង១២នាក់ក៏នាំគ្នាដើរក្នុងព្រៃទៅដល់នគរមួយជានគរយក្សស្រីឈ្មោះនាងសន្ធមារ ។ យក្សនោះមានកូនស្រីមួយឈ្មោះនាងកង្រី ។ នាងសន្ធមារបានឃើញនាងទាំង១២នាក់ ក៏ដំណែងខ្លួនជាស្រី នាំយកនាងទាំងនោះទៅទុកក្នុងប្រាសាទរបស់ខ្លួន ឱ្យបម្រើនាងកង្រីជាកូន ។

កាលនោះនាងទាំង១២នាក់ដឹងថា នគរនោះជានគរយក្ស នាងសន្ធមារជាយក្ខិនី ហើយក៏នាំគ្នារត់ចេញ ។ នាងសន្ធមារបានតាមរកឃើញ នាងទាំង១២ បានក្លាយជាមហេសីព្រះបាទរថសិទ្ធិ នៅនគរមនុស្សទៅហើយ ។ ពេលនោះនាងសន្ធមារក៏ដំណែងខ្លួនជាស្រីក្រមុំ ហើយក៏បានធ្វើជាមហេសីព្រះបាទរថសិទ្ធិដែរ ។ នាងសន្ធមារពុតធ្វើជាឈឺធ្ងន់ញុះញង់ពេទ្យឱ្យទូលព្រះបាទរថសិទ្ធិឱ្យឆ្កៀលភ្នែកទាំង ១២ យកមកធ្វើជាថ្នាំព្យាបាលរោគខ្លួននិងឱ្យយកនាងទាំង ១២នាក់ដែលមានគភ៌គ្រប់គ្នាទៅទុកក្នុងរណ្ដៅមួយជាមួយគ្នា បង្អត់អាហារ ឱ្យយកគ្រាប់ភ្នែករបស់នាងទាំង ១២នាក់នោះទៅទុកក្នុងឃ្លាំងឯនគររបស់ខ្លួន ដោយទុកឱ្យនាងកង្រីជាកូនថែរក្សា ។

ក្នុងចំណោមនាងទាំង ១២នាក់នោះ នាងបងៗ ១១នាក់ត្រូវគេឆ្កៀលភ្នែកទាំងសងខាង ឯនាងពៅត្រូវគេឆ្កៀលភ្នែកតែម្ខាង ដោយពីជាតិមុននាងពៅឆ្កៀលភ្នែកត្រីតែម្ខាងដែរ ។ ពេលនាងទាំង១២មានគភ៌នោះ នាងពៅបានត្រូវព្រះពោធិសត្វមកចាប់ផ្ទៃ ។ វេលានាងបងៗកើតកូនភ្លាម គេហែកកូនចែកសាច់គ្នាស៊ីអស់ ចំណែកនាងពៅកើតកូនមកឱ្យឈ្មោះថា "ពុទ្ធិសែន" ហើយលាក់ទុកមិនឱ្យនាងបងៗដឹងទេ ។

ចំណេរកាលខាងក្រោយមក វេលាពុទ្ធិសែនធំពេញជំទង់ឡើង នាងសន្ធមារដឹងថាជាកូននាងទី ១២ ក៏ប្រើឱ្យជិះសេះនាំសំបុត្រទៅឱ្យកង្រីដោយដាក់សេចក្ដី ៖ "បើពុទ្ធិសែនមកដល់ពេលយប់ ឱ្យស៊ីទាំងយប់មកដល់ថ្ងៃឱ្យស៊ីទាំងថ្ងៃ" ។ តែជាភ័ព្វរបស់ពុទ្ធិសែន នៅពេលជិះសេះទៅដល់ពាក់កណ្ដាលព្រៃ មហាឫសីបានឃើញពុទ្ធិសែនកំពុងផ្ទំលក់និងឃើញសំបុត្រ ដែលចងនៅនឹងសេះ ក៏ហែកសំបុត្រ





នោះចោល ហើយសរសេរសំបុត្រជាថ្មី ៖ "បើពុទ្ធិសែនមកដល់យប់ឱ្យរៀបការទាំងយប់ ដល់ថ្ងៃរៀបការទាំងថ្ងៃជាមួយនាងកង្រីជាកូន" ។ ពេលដែលពុទ្ធិសែនបានសោយរាជ្យ នៅនគរយក្សមិនយូរប៉ុន្មានពុទ្ធិសែនក៏ជ្រាបដំណឹងអំពីប្រវត្តិប្រស្រីភ្នែកមាតាខ្លួននិងអំពីថ្នាំសម្រាប់ដាក់ភ្នែកឱ្យជាសះស្បើយ និងថ្នាំសម្រាប់បោះទៅកើតជាទឹកសមុទ្រ ជាភ្នំបាន ទ្រង់ក៏លួចរត់ចោលនាងកង្រីទាំងអធ្រាត្រ ។ នាងកង្រីរត់តាមមិនទាន់ក៏យំសោកស្លាប់នៅកណ្ដាលព្រៃ ហើយព្រះពុទ្ធិសែនមកដល់នគរវិញដោយសុវត្ថិភាព ទ្រង់ដាក់ថ្នាំកែវភ្នែកមាតានិងមាតាធំទាំងអស់ឱ្យជាឡើងវិញ ។ ព្រះអង្គក៏សម្លាប់នាងសន្ធមារទៅ ទ្រង់បានសោយរាជ្យជំនួសបិតា ជាសុខក្សេមក្សាន្តរហូតដល់ទ្រង់ចូលទិវង្គត ។ [...]

*(ដកស្រង់និងកែសម្រួលពីប្រជុំរឿងព្រេងខ្មែរភាគ៥ ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥៤៧ គ.ស.២០០៣ ទំព័រទី ៩៤-១០០)*

## សំណួរ

១. តើរឿងនេះគេចាត់ទុកជាអក្សរសិល្ប៍ប្រភេទណា ? ចូររកអំណះអំណាងបញ្ជាក់ ។

២. ហេតុដូចម្ដេចបានជានាងទាំង១១ ត្រូវគេឆ្កៀលភ្នែកទាំងសងខាង ? ឯនាងទី១២ ត្រូវគេឆ្កៀលភ្នែកតែម្ខាង ? តាមគំនិតអ្នក តើឥទ្ធិពលនៃទស្សនៈនេះកើតមកពីណា ?

៣. តើផ្នត់គំនិតណាមួយក្នុងអត្ថបទដែលនៅតែជាឧត្ដមគតិដ៏ល្អសម្រាប់កូនខ្មែរជំនាន់ក្រោយ ? ហេតុអ្វី ?

៤. តើរឿងនេះ បានបង្ហាញពីផ្នត់គំនិតខ្មែរយ៉ាងណាខ្លះ ?

៥. ហេតុដូចម្ដេចបានជាពុទ្ធិសែន បានរៀបការជាមួយនាងកង្រី ? តើអ្នកនិពន្ធមានទស្សនៈដូចម្ដេច ទើបមិនឱ្យពុទ្ធិសែនបានរួមរស់ជាមួយនាងកង្រីជាគូរៀងទៅអនាគត ?

៦. បើតាមទស្សនៈរបស់អ្នក តើការបញ្ចប់រឿងដោយឱ្យពុទ្ធិសែន និងនាងកង្រីមិនបានរួមរស់ជាស្វាមីភរិយាលុះអនាគតបែបនេះសមស្របឬទេ ? ហេតុអ្វី ?

៧. ចូរសិក្សាពីកាលអាកាសនៃរឿង ។

៨. ចូរអ្នកស្រង់ពាក្យក្លាយឱ្យបានបួនពាក្យពីក្នុងអត្ថបទអំណានរឿង "ភ្នំនាងកង្រី" ដោយបង្ហាញពាក្យឫសនិងប្រាប់ពីទម្រង់ផង ។